# បុណ្យលើកតម្កើងព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ
# ព្រះសហគមន៍សន្តិម៉ារីញញឹម ចំការទៀង
# ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១
## "ទំនាក់ទំនង"

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងគោរពបុណ្យលើកតម្កើងព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ជាពេលវេលាមួយដើម្បីណែនាំឱ្យយើងរកឃើញដូចជាដង្ហើមថ្មី អំណរសប្បាយថ្មី កម្លាំងថ្មី នៅក្នុងបរិយាកាសដែលប្រែប្រួលពីប៉ុន្មានខែកន្លងមកហើយ។ ពិតមែន នៅក្នុងព្រះនាងម៉ារីគឺមនុស្សលោកថ្មីដែលកំពុងកើតឡើង នៅក្នុងព្រះនាងម៉ារីគឺការសង្គ្រោះដែលយើងមើលឃើញផ្ទាល់ភ្នែក នៅក្នុងព្រះនាងម៉ារីគឺព្រះយេស៊ូដែលប្រសូត។ ជាព្រះសង្គ្រោះរបស់យើង ដែលប្រសូតដូចយើងបានស្តាប់នៅក្នុងអត្ថបទទី១ "**ពេលនោះ ខ្ញុំបានលឺសម្លេងមួយបន្លឺយ៉ាងខ្លាំងទៅលើមេឃថា ឥឡូវនេះដល់ពេលព្រះជាម្ចាស់សង្គ្រោះមនុស្សលោកហើយ ហើយឫទ្ធានុភាពនិងព្រះរាជរបស់ព្រះជាម្ចាស់របស់យើង ព្រមទាំងអំណាចព្រះគ្រីស្តរបស់ព្រះអង្គក៏បានមកដល់ដែរ**"។ នៅក្នុងព្រះនាងម៉ារីពិតមែនយើងមើលឃើញសេចក្តីសង្ឃឹមនៅលើជីវិតអស់កល្បជានិច្ច។

បងប្អូនជាទីស្រឡាញ់ ថ្ងៃនេះជាពេលវេលាមួយដើម្បីទទួលកម្លាំងថ្មីតាមរយៈព្រះនាងម៉ារី ដោយសារនៅពេលយើងស្តាប់អត្ថបទទី១ អត្ថបទទី២ និងជាពិសេសអត្ថបទដំណឹងល្អ យើងបានរំភើបនៅក្នុងអំណរសប្បាយរួមជាមួយព្រះនាងម៉ារី។ ថ្ងៃនេះយើងបានរៀបចំកន្លែងមួយយ៉ាងប្លែក ដែលយើងបានឃើញរូបព្រះនាងម៉ារីនៃទីក្រុង ឡួដ៍ ដែលពោរពេញដោយផ្កាកូលាប។ ផ្កាពណ៌សជានិមិត្តរូបនៃជីវិតដ៏វិសុទ្ធ ផ្កាពណ៌ផ្កាឈូកជានិមិត្តរូបនៃសេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ យើងមានទឹកដែលណែនាំឱ្យយើងមានអារម្មណ៍ថាត្រជាក់ត្រជុំ។ យើងពោរពេញដោយអំណរសប្បាយរួមជាមួយព្រះនាងម៉ារី ដោយសារព្រះនាងម៉ារីក៏ពោរពេញដោយអំណរសប្បាយដែរ។

យើងបានឃើញថ្ងៃនេះ នៅពេលព្រះនាងម៉ារីបានទទួលដំណឹងថាមានផ្ទៃពោះហើយ ព្រះនាងមិនបានទន្ទឹងរង់ចាំដើម្បីទុកអំណរសប្បាយសម្រាប់ព្រះនាងផ្ទាល់ខ្លួន ផ្ទុយទៅវិញព្រះនាងម៉ារីប្រញាប់ប្រញាល់ធ្វើដំណើរទៅកាន់ភូមិនៅតំបន់ភ្នំ ដើម្បីទៅសួរសុខទុក្ខយាយអេលីសាបែតដែលជាបងជីដូនមួយរបស់ព្រះនាង។ នៅពេលនោះ ព្រះនាងម៉ារីបានធ្វើដំណើរអស់៧ថ្ងៃ៧យប់ ទាំងថ្ងៃក្តី ទាំងយប់ក្តី ទាំងក្តៅក្តី ប៉ុន្តែព្រះនាងម៉ារីបានប្រញាប់ប្រញាល់ដើម្បីចែករំលែកអំណរសប្បាយ។ នៅពេលគាត់ជួបគ្នាភ្លាម មិនទាន់និយាយមួយម៉ាត់នៅពេលនោះទារកដែលនៅក្នុងផ្ទៃយាយអេលីសាបែត បានបម្រះឡើងដោយសារទារកក៏ដឹងដែរថា ព្រះនាងម៉ារីពោរពេញទៅដោយអំណរសប្បាយនៅក្នុងខ្លួន។ អំណរសប្បាយនេះ ដូចជាបានឆ្លងមកដល់យាយអេលីសាបែត ឆ្លងមកដល់ទារកដែលនៅក្នុងផ្ទៃពោះយាយអេលីសាបែត។

ថ្ងៃនេះ ជាថ្ងៃដែលយើងពោរពេញដោយអំណរសប្បាយរួមជាមួយព្រះនាងម៉ារី នៅពេលនោះភ្លាមៗព្រះនាងម៉ារីចាប់ផ្តើមថ្លែងឡើងថា "**ព្រលឹងខ្ញុំសូមលើកតម្កើងព្រះអម្ចាស់ ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំង ព្រោះព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ ព្រះអង្គទតមកមើលទុក្ខវេទនានៃអ្នកបម្រើរបស់ព្រះអង្គ អំណះតទៅមនុស្សគ្រប់ជំនាន់នឹងពោលថា ខ្ញុំជាអ្នកមានសុភមង្គលពិតមែន ព្រះដ៏មានឫទ្ធានុភាពបានសម្តែងការប្រសើរអស្ចារ្យចំពោះរូបខ្ញុំ**"។ ថ្ងៃនេះ យើងត្រូវតែទទួលពាក្យរបស់ព្រះនាងម៉ារីសម្រាប់ជីវិតរបស់យើងដែរ។ ប្រហែលបងប្អូនកំពុងគិតថា និយាយយ៉ាងស្រួលប៉ុន្តែពេលយើងឃើញស្ថានភាពនិងបរិយាកាសរបស់យើងសព្វថ្ងៃយើងពិបាកស្រែកឡើងថា "**ព្រលឹងខ្ញុំសូមលើកតម្កើងព្រះអម្ចាស់ ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំង ខ្ញុំមានសុភមង្គលពិតមែន**"។ ដោយសារបើយើងមើលសង្គមយើងបច្ចុប្បន្ននេះណែនាំឱ្យយើងភ័យខ្លាច ណែនាំឱ្យយើងមិនដឹងធ្វើអ្វីពីមួយថ្ងៃទៅមួយថ្ងៃ។ យើងសង្ឃឹមថាបើកសាលាវិញ ប៉ុន្តែយើងមិនទាន់ដឹងថាថ្ងៃណាឡើយ យើងសង្ឃឹមបើកសង្គមវិញផ្ទុយទៅវិញ បានថែមពីរសប្តាហ៍ទៀតដោយបិទគ្រប់ទីកន្លែង ដែលណែនាំឱ្យយើងកំសាន្ត ណែនាំឱ្យយើងសប្បាយ ណែនាំឱ្យយើងជួបជុំគ្នា...។ ហេតុនេះហើយ សេចក្តីសង្ឃឹមតាមលោកីយបីដូចជាគាំងអស់ហើយ ប៉ុន្តែថ្ងៃនេះយើងចូលនៅក្នុងសេចក្តីសង្ឃឹមតាមជំនឿ សេចក្តីសង្ឃឹមតាមជំនឿមិនគាំងសោះ។ នៅក្នុងព្រះនាងម៉ារី យើងអាចថ្លែងឡើងថា "**ព្រលឹងខ្ញុំសូមលើកតម្កើងព្រះអម្ចាស់ ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំង**"។

ពិតមែន បងប្អូនជាទីស្រឡាញ់ថ្ងៃនេះជាពេលវេលាមួយដើម្បីផ្លាស់ប្តូរអារម្មណ៍របស់យើង ដើម្បីផ្លាស់ប្តូររបៀបរបស់យើង។ ដោយសារ ព្រះនាងម៉ារីបានបើកផ្លូវនៃមនុស្សលោកថ្មី ព្រះនាងម៉ារី

បានបើកផ្លូវនៃស្ថានបរមសុខសម្រាប់យើង។ នៅពេលខ្ញុំកំពុងទេសនាបងប្អូនបានឃើញ ព្រះអាទិត្យកំពុងរះឡើងដើម្បីបង្ហាញថាផ្ទៃមេឃថ្មីកំពុងកើតឡើង ព្រះអាទិត្យថ្មីកំពុងកើតឡើង ជីវិតថ្មីកំពុងកើតឡើង នៅពេលព្រះនាងម៉ារីបានឡើងស្ថានបរមសុខមុនគេបង្អស់។ បងប្អូនជាទីស្រឡាញ់ ប៉ុន្មានដងយើងធ្លាប់និយាយថា នៅក្នុងពេលវេលាដ៏ពិបាកនេះ នៅក្នុងបរិយាកាសដ៏ពិបាកនេះ នៅក្នុងស្ថានភាពដ៏ពិបាកនេះដោយនឹកឃើញកូវីដ-១៩។ ប្រសិនបើ យើងបើកទស្សនាវដ្ដី យើងបើកហ្វេសបុក យើងបើកព័ត៌មាន យើងឃើញមាន៩០%នៃព័ត៌មាននិយាយតែអំពីកូវីដ-១៩ និយាយតែអំពីមនុស្សស្លាប់ និយាយតែអំពីទុក្ខលំបាកដែលយើងជួបសព្វថ្ងៃ។ ៩០%នៃព័ត៌មានពីប៉ុន្មានខែកន្លងមក ណែនាំឱ្យខួរក្បាលរបស់យើងចាប់ផ្ដើមវិល ប៉ុន្តែមិនវិលចេញពីភាពកំសត់ ការពិបាក ភ័យខ្លាចអ្វីសោះ។

ប៉ុន្តែថ្ងៃនេះ ខ្ញុំសូមអញ្ជើញបងប្អូនចាប់ផ្ដើមដូររបៀបមើលឃើញ កុំឱ្យយើងនិយាយថាយើងរស់នៅក្នុងស្ថានភាពដ៏ពិបាក កុំឱ្យយើងនិយាយថាយើងរស់នៅក្នុងកាលៈទេសៈដ៏ពិបាក កុំឱ្យយើងនិយាយថាយើងរស់នៅក្នុងពេលវេលាដ៏ពិបាក។ ផ្ទុយទៅវិញ ឱ្យយើងនិយាយថាយើងរស់នៅក្នុងស្ថានភាពដែលប្រែប្រួល យើងមិនមែនដូចធម្មតាដូចយើងធ្លាប់ស្គាល់ ទៅព្រះវិហាររាល់សប្ដាហ៍ ទៅសាលារាល់ថ្ងៃ ទៅធ្វើការធម្មតា ទៅសួរសុខទុក្ខគ្នាបាន...។ យើងលែងរស់នៅក្នុងរបៀបហ្នឹងមែន ប៉ុន្តែកុំឱ្យយើងប្រើពាក្យពិបាក ប្រសិនបើយើងចេះតែនឹកឃើញពិបាកៗ ណែនាំឱ្យយើងបាត់បង់សេចក្ដីសង្ឃឹមរបស់យើង។ យើងចេះតែមើលឃើញឧបសគ្គ ដែលរាំងផ្លូវនៃជីវិតរបស់យើងជាប្រចាំថ្ងៃ។ ផ្ទុយទៅវិញ ប្រសិនបើយើងដូររបៀបគិត ដោយគិតថាឥឡូវនេះយើងរស់នៅក្នុងបរិយាកាស ពេលវេលា ដែលប្រែប្រួលនិងដែលណែនាំឱ្យយើងចេះមើលឃើញអ្វីដែលល្អដែរឱ្យចេះមើលឃើញអ្វីដែលណែនាំឱ្យយើងមានសេចក្ដីសង្ឃឹមដែរ។

ម្សិលមិញ នៅព្រះសហគមន៍សន្តសិលា និងសន្តប៉ូលភ្នំពេញថ្មី យើងមានមនុស្សពេញវ័យ១២នាក់ បានទទួលអគ្គសញ្ញាជ្រមុជទឹក។ គេទន្ទឹងរង់ចាំពីយូរខែមកហើយ ដោយយើងមានច្បាប់អាចជួបជុំគ្នាតែ១៥នាក់ យើងបានធ្វើពិធីជ្រមុជទឹកសម្រាប់បេក្ខជន១២នាក់។ នេះជាសញ្ញាមួយដែលណែនាំឱ្យយើងមានសេចក្ដីសង្ឃឹម។ ម្សិលមិញពេលព្រឹក ខ្ញុំបានប្រមូលគ្រូអប់រំជំនឿក្នុងភូមិភាគភ្នំពេញទាំងមូល យើងបានជួបគ្នាពីចម្ងាយជាង៦០នាក់។ ពេលយើងបានជួបជុំគ្នា ពេលយើងបានស្ដាប់អំពីបទពិសោធន៍គ្នាទៅវិញទៅមក ដើម្បីបង្រៀនអប់រំជំនឿពីចម្ងាយ ដើម្បីបង្រៀនក្រុមតូចៗ ដើម្បីណែនាំឱ្យបងប្អូនដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បន្តមានទំនាក់ទំនងជាមួយព្រះសហគមន៍ ទំនាក់ទំនងជាមួយព្រះជាម្ចាស់ ណែនាំឱ្យយើងមានសេច

ក្ដីសង្ឃឹម។ ប្រសិនបើបងប្អូនជាប់ជាមួយ យូធូប ហ្វេសបុករបស់ព្រះសហគមន៍យើង ឃើញរាល់ថ្ងៃកម្មវិធី "**២នាទីសម្រាប់ស្មារតីរបស់យើង**" ដោយខ្ញុំបានរើសរូបទេសភាព ផ្កា សត្វយ៉ាងល្អមើល ដើម្បីណែនាំឱ្យយើងយល់ថាជីវិតរបស់យើងមិនមែនគាំងទេ ជីវិតរបស់យើងមិនមែនពោរពេញដោយទុក្ខលំបាកទេ ជីវិតរបស់យើងមានសេចក្ដីសង្ឃឹមតទៅទៀត។

ពិតមែន ថ្ងៃនេះពីស្ថានបរមសុខយើងដឹងថាព្រះនាងម៉ារីកំពុងសម្លឹងមើលយើង នៅក្បែរព្រះយេស៊ូពីស្ថានបរមសុខព្រះនាងម៉ារីកំពុងផ្ដល់កម្លាំងឱ្យយើង ដើម្បីឱ្យយើងហ៊ានថ្លែងឡើងថា "**ព្រលឹងខ្ញុំសូមលើកតម្កើងព្រះអម្ចាស់ ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំង ខ្ញុំដឹងថាចាប់ពីពេលនេះតទៅខ្ញុំមានសុភមង្គលដ៏ពេញលក្ខណៈ**"។ ដូច្នេះ បងប្អូនជាទីស្រឡាញ់យើងត្រូវការសួរសំណួរនេះ **តើយើងចង់បង្កើតពិភពអ្វីសម្រាប់កូនរបស់យើង សម្រាប់បងប្អូនរបស់យើង សម្រាប់អនាគតរបស់យើង?** ពេលយើងចូលក្នុងព្រឹត្តិការណ៍ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ យើងគិតថាមិនអីទេប្រហែលដូចពីមុនយើងមានព្រឹត្តិការណ៍ច្រើនដងដែរ ១ខែ ២ខែ...។ ដូច្នេះ យើងដូចជាស្ទះបន្តិចចាំមើល២សប្ដាហ៍ទៀត ចាំមើល១ខែទៀត រហូតដល់ឥឡូវនេះជិត៦ខែហើយ។ យើងមិនដឹង ទោះបីយើងបានចាក់វ៉ាក់សាំងបង្ការជំងឺនេះយ៉ាងច្រើនក៏ដោយ ប៉ុន្តែយើងមិនទាន់ដឹងសញ្ញាមួយដែលណែនាំឱ្យយើងបើកទ្វារនៃជីវិតធម្មតា។ ហេតុនេះហើយ យើងមិនអាចតែទន្ទឹងរង់ចាំចាំមើលថ្ងៃស្អែក បងប្អូនជាទីស្រឡាញ់ឱ្យយើងមើលថ្ងៃនេះ **តើយើងមើលអ្វីខ្លះដើម្បីឱ្យកូនរបស់យើងរៀបចំអនាគត? ថ្ងៃនេះតើយើងធ្វើអ្វីខ្លះដើម្បីឱ្យបងប្អូនរបស់យើង ទទួលការអប់រំជំនឿត្រឹមត្រូវ? ថ្ងៃនេះតើយើងធ្វើអ្វីខ្លះដើម្បីអធិដ្ឋាន ដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់?** កុំឱ្យសេចក្ដីសង្ឃឹមរបស់យើងធ្លាក់ចុះ **ថ្ងៃនេះតើយើងធ្វើអ្វីខ្លះដើម្បីមើលឃើញពិភពរបស់យើងដោយភ្នែកថ្មី?**

ដោយសារស្ថានភាពប្រែប្រួល នេះជាអ្វីដែលយើងត្រូវថែរក្សា។ នេះជាមេរៀនសម្រាប់យើងថ្ងៃនេះនៅក្នុងគម្ពីរដំណឹងល្អ គឺ**ទំនាក់ទំនង** ព្រះនាងម៉ារីនៅសម័យនោះឥតមានហ្វេសបុក ឥតមានវ៉ាត់អេប ដើម្បីផ្ញើសារសួរសុខទុក្ខដល់យាយអេលីសាបែត។ ព្រះនាងម៉ារីបានធ្វើដំណើរអស់៧ថ្ងៃ ដើម្បីទៅសួរសុខទុក្ខយាយអេលីសាបែតផ្ទាល់ នៅក្នុងអំណរសប្បាយ នៅក្នុងការតស៊ូ។ គាត់មានផ្ទៃពោះ គាត់អស់កម្លាំង ប្រហែលចាញ់កូនទៀតមិនដឹងថាក្អួតប៉ុន្មានដងប៉ុន្មានសារនៅតាមផ្លូវ ក៏ប៉ុន្តែគាត់បានទៅនិងលើកតម្កើងព្រះជាម្ចាស់នៅគ្រប់ពេលវេលារបស់គាត់។ អ្វីដែលសំខាន់បងប្អូនជាទីស្រឡាញ់ គឺទំនាក់ទំនង ទំនាក់ទំនងជាមួយព្រះជាម្ចាស់ ទំនាក់ទំនងជាមួយបងប្អូនឯទៀតៗ ទំនាក់ទំនងជាមួយយើងផ្ទាល់ខ្លួននៅក្នុងសុខភាព នៅក្នុងរូបកាយរបស់យើង។

សប្តាហ៍មុនខ្ញុំបាននិយាយអំពីសត្វទា ថ្ងៃនេះខ្ញុំសុំនិយាយអំពីសត្វទន្សាយម្តង ប៉ុន្មានថ្ងៃមុនខ្ញុំបានទទួលទន្សាយថ្មីមួយ និងខ្ញុំមានទន្សាយចាស់មួយដែរ។ ខ្ញុំមិនបាននៅ២ថ្ងៃ ពេលខ្ញុំត្រលប់មកវិញខ្ញុំមិនបានឃើញទន្សាយថ្មីនោះសោះ តាមពិតវាចូលនៅក្នុងរូង វាបានកាយដីជ្រៅទៅៗ ហើយវាចូលទៅនៅទីនោះ។ ហេតុនេះហើយ ទន្សាយដែលនៅពីយូរហើយវាដូចជាកំសត់ទុរគត ដោយសារបានដៃគូរប៉ុន្តែដៃគូរចូលទៅក្នុងរូង មិនបង្កើតទំនាក់ទំនងរវាងគ្នានឹងគ្នាសោះ។ ម្យ៉ាងវិញ ពេលមានភ្លៀងវាចេញពីរូង ទន្សាយទាំងពីរក្បាលនៅជិតគ្នាដើម្បីផ្តល់ភាពកក់ក្តៅឱ្យគ្នាទៅវិញទៅមក ដោយសារកំពុងរងាព្រោះតែទឹកភ្លៀងខ្លាំង នៅពេលនោះមើលទៅដូចជាវាសប្បាយមែនទែន។ ដូច្នេះ យើងត្រូវការសម្រេចចិត្ត **តើយើងទៅជាមនុស្សដែលកាយដី ដែលចូលនៅក្នុងបន្ទប់ចាក់សោរបិទទំនាក់ទំនងទាំងអស់ ឬយើងជាមនុស្សដែលចេះរកមធ្យោបាយថ្មី ដើម្បីបង្កើតទំនាក់ទំនង ដើម្បីផ្តល់ភាពកក់ក្តៅឱ្យគ្នាទៅវិញទៅមក ដើម្បីផ្តល់ការលើកទឹកចិត្តគ្នាទៅវិញទៅមក នៅក្នុងកាលៈទេសៈដែលប្រែប្រួលដូចសព្វថ្ងៃនេះ?**

កុំឱ្យយើងទៅជាទន្សាយដែលចូលនៅក្នុងរូង ដែលកាយដីជ្រៅទៅៗពីមួយថ្ងៃទៅមួយថ្ងៃ ឱ្យយើងទៅជាមនុស្សម្នាក់ដែលបន្តបង្កើតទំនាក់ទំនងរវាងគ្នានឹងគ្នា ដើម្បីណែនាំឱ្យជីវិតរបស់យើងមានក្លិនដ៏ក្រអូប មានខ្លឹមដែលពោរពេញដោយតម្លៃ។ មានអ្នកខ្លះនិយាយថា សព្វថ្ងៃជីវិតស៊ីសង យើងមើល ជីវិតរបស់យើងជួនកាលដូចទឹកប្រៃ ជួនកាលដូចទឹកសាប នេះមិនសំខាន់ទេ។ អ្វីដែលសំខាន់បំផុតនោះគឺ ជីវិតរបស់យើងឱ្យពោរពេញដោយទឹកដែលមកពីព្រះជាម្ចាស់ផ្ទាល់ ជាទឹកនៃអំណរ ជាទឹកដែលណែនាំឱ្យយើងមានជីវិត ជីវិតអស់កល្បជានិច្ច។

បងប្អូនជាទីស្រឡាញ់ ថ្ងៃនេះយើងសម្លឹងមើលម្តងទៀតផ្កាដ៏ស្អាតនៅជុំវិញព្រះនាងម៉ារី ឱ្យយើងស្តាប់សម្លេងដ៏ពីរោះនៃទឹកដែលកំពុងហូរចេញពីលើថ្ម ដើម្បីណែនាំឱ្យយើងមានភាពកក់ក្តៅ ណែនាំឱ្យយើងមានអំណរជាមួយព្រះនាងម៉ារី ណែនាំឱ្យយើងយល់ថា ជីវិតរបស់យើងមិនមែនដូចពីមុនមែនប៉ុន្តែជីវិតរបស់យើង គឺជាអំណោយទានដែលយើងបានទទួលពីព្រះជាម្ចាស់។ យើងដឹងថា ដោយសារព្រះនាងម៉ារីជីវិតរបស់យើងទៅមុខ និងព្រះនាងម៉ារីបានបើកផ្លូវនៃស្ថានបរមសុខដើម្បីឱ្យយើងមានជីវិតអស់កល្បជានិច្ច នេះជាសេចក្តីសង្ឃឹមរបស់យើង។ ហេតុនេះហើយ រួមជាមួយព្រះនាងម៉ារីម្តងទៀតយើងថ្លែងឡើងថា "**ព្រលឹងខ្ញុំសូមលើកតម្កើងព្រះអម្ចាស់ ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំង ព្រោះព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ ពិតមែនខ្ញុំជាអ្នកមានសុភមង្គល**"។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ៉ ជ្មឹតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ